គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

# សាររបស់សម្តេច ជា ស៊ីម
## ប្រធានគណបក្សប្រជាជនកម្ពុជា ជូនចំពោះប្រជាជនកម្ពុជា

សូមក្រាបថ្វាយបង្គំសម្តេច ព្រះសង្ឃរាជ ទាំង ២ គណៈ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ
ជនរួមជាតិ ជាទីគោរពស្នេហា !

ការបោះឆ្នោតជ្រើសរើសរដ្ឋសភានីតិកាលទី៣ នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៣ កន្លងមកនេះ បានប្រព្រឹត្តទៅយ៉ាងជោគជ័យ ដោយមានលក្ខណៈសេរី យុត្តិធម៌ មានតម្លាភាព សុវត្ថិភាព និងជឿទុកចិត្តបានទាំងស្រុង ។ ប្រជាជនកម្ពុជា ដែលមានសិទ្ធិបោះឆ្នោត បានអនុវត្តយ៉ាងពេញលេញនូវសិទ្ធិដ៏ពិសិដ្ឋរបស់ខ្លួន ដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ដោយបានចេញទៅបោះឆ្នោតយ៉ាងច្រើនកុះករ នៅតាមការិយាល័យបោះឆ្នោតនានា នៅទូទាំងប្រទេស ដើម្បីជ្រើសរើសតំណាងរបស់ខ្លួន សំរាប់ដឹកនាំប្រទេសបន្តទៀត ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ចំពោះជោគវាសនាអនាគតនៃមាតុភូមិ ក៏ដូចជាជោគវាសនាខ្លួនឯងផ្ទាល់ ។ សាធារណមតិក្នុងប្រទេស និងក្រៅប្រទេស ក៏បានវាយតម្លៃខ្ពស់ចំពោះការបោះឆ្នោតនេះ ។ នេះគឺជាសមិទ្ធផលដ៏ធំធេងមួយថ្មីទៀត នៃព្រះរាជាណាចក្រកម្ពុជា ដែលកំពុងបោះជំហានទៅមុខយ៉ាងរឹងមាំនៅលើមាគ៌ាប្រជាធិបតេយ្យ និងនីតិរដ្ឋ ហើយបានឆ្លុះបញ្ចាំងច្បាស់នូវបំណងប្រាថ្នារបស់ប្រជាជនយើង គឺសន្តិភាព ឯកភាពជាតិ និងការអភិវឌ្ឍន៍ ។

ផ្អែកលើមូលដ្ឋាននេះ គណបក្សប្រជាជនកម្ពុជា សូមប្រកាសជាឧឡារិកគាំទ្រទាំងស្រុងលទ្ធផលនៃការបោះឆ្នោត ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានប្រកាសនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០៣ ហើយប្តេជ្ញាការពារដាច់ខាតនូវលទ្ធផលនៃការបោះឆ្នោតនេះ ដែលផុសចេញពីឆន្ទៈរបស់ប្រជាជនយ៉ាងពិតប្រាកដ ។ គ្មានមជ្ឈដ្ឋានអ្នកនយោបាយណា អាចមកបំផ្លាញលទ្ធផលនៃការបោះឆ្នោតនេះបានឡើយ ។

គណបក្សប្រជាជនកម្ពុជា សូមសំដែងនូវការគោរពដ៏ខ្ពង់ខ្ពស់ និងកតញ្ញុតាធម៌ជ្រាលជ្រៅបំផុត ជូនជនរួមជាតិនៅគ្រប់ទិសទី ដែលបានផ្តល់យុត្តិធម៌ដល់គណបក្សក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ឆ្លងកាត់ដំណាក់កាលនានាជាបន្តបន្ទាប់មក ហើយបានសំរេចចិត្តបោះឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជា យ៉ាងច្រើនលើសលុប ដើម្បីឱ្យគណបក្សមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការដឹកនាំប្រទេសបន្តទៀត ។ ការសំរេចចិត្តដ៏ឧត្តុង្គឧត្តមនេះ បានស្តែងឱ្យឃើញច្បាស់ថា ប្រជាជនកម្ពុជា នៅតែចងចាំជានិច្ចនូវសមិទ្ធផលថ្ងៃជ័យជំនះ ៧ មករា ប្រជាជនមានការជឿជាក់ ហើយនៅតែត្រូវការតួនាទីដឹកនាំរបស់គណបក្សទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ។ ការគាំទ្រដ៏ធំធេងនេះ គឺជាកត្តាចំបងបំផុត ដើម្បីធានាជ័យជំនះក្នុងការអនុវត្តន៍កម្មវិធីនយោបាយរបស់គណបក្សនាពេលអនាគត ។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ទូលព្រះបង្គំសូមសំដែងការគោរពភក្តី និងកតញ្ញុតាធម៌ដ៏ជ្រាលជ្រៅបំផុត ថ្វាយព្រះករុណា ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេច **ព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ដែលបានបូជាអស់ព្រះកាយពល និងព្រះបញ្ញាញាណ ដើម្បីសេចក្តីសុខ សេចក្តីចំរើនរបស់ប្រទេសជាតិ និងប្រជារាស្ត្រ។ ព្រះអង្គជានិមិត្តរូបដ៏ខ្ពង់ខ្ពស់បំផុតនៃឯកភាពជាតិ និងនិរន្តរភាពជាតិ ជាព្រះបិតាឯករាជជាតិ និងបង្រួបបង្រួមជាតិ។ ព្រះអង្គទ្រង់គង់ជាអព្យាក្រឹតឥតលំអៀង បានប្រទានយុត្តិធម៌ឱ្យគ្រប់គណបក្សនយោបាយ ក្នុងការស្វែងរកសំលេងគាំទ្ររៀងៗខ្លួនតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស។ ទូលព្រះបង្គំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យវត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតារក្សាព្រះមហាស្វេតច្ឆ័ត្រ និងព្រះវិញ្ញាណក្ខន្ធនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ សូមជួយប្រោះព្រំ បីបាច់ថែរក្សាព្រះករុណាជាអម្ចាស់ និងសម្តេចព្រះរាជអគ្គមហេសី ជាទីសក្ការៈ ដើម្បីព្រះអង្គបានគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់របស់ប្រជារាស្ត្រ ជាកូនចៅ ចៅទួត ជារៀង ដរាប ។

ខ្ញុំសូមថ្លែងនូវការកោតសរសើរ និងអំណរគុណដ៏ស្មោះចំពោះគណៈកម្មាធិការគណបក្សគ្រប់ថ្នាក់ មន្ត្រី សមាជិក សមាជិកាគណបក្សប្រជាជនកម្ពុជាគ្រប់រូប ដែលបានយកអស់ស្មារតី រក្សាសាមគ្គីភាព ឯកភាពរឹងមាំ ខិតខំអនុវត្តការកិច្ចជូនគណបក្ស ហើយបានប្រកាន់ខ្ជាប់នូវចិត្តខន្តី និងអហិង្សានៅក្នុងគ្រប់សកម្មភាពទាំងអស់ ។ នេះគឺជាកត្តាដ៏ចំបងមួយនៃជោគជ័យរបស់គណបក្សយើង ។

គណបក្សប្រជាជនកម្ពុជា សូមវាយតម្លៃខ្ពស់ ចំពោះសកម្មភាពរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការបោះឆ្នោតថ្នាក់ខេត្ត ក្រុង ឃុំ សង្កាត់ ព្រមទាំងមន្ត្រីបំពេញការងារបោះឆ្នោតនៅគ្រប់ថ្នាក់ ដែលបានពុះពារបំពេញភារកិច្ចយ៉ាងលំបាកស្មុគស្មាញដែលជាតិនិងប្រជាជនប្រគល់ឱ្យ ប្រកបដោយភាពឯករាជ្យ អព្យាក្រឹត មិនលំអៀង មានតម្លាភាព និងផ្អែកលើគោលការណ៍ច្បាប់ រហូតសំរេចបានជោគជ័យដ៏ត្រចះត្រចង់ ។ ព្រមជាមួយនេះ សូមវាយតម្លៃខ្ពស់ ចំពោះស្ថាប័ននានានៃរាជរដ្ឋាភិបាល កម្លាំងមានសមត្ថកិច្ច និងអាជ្ញាធរគ្រប់ថ្នាក់ ដែលបានអនុវត្តយ៉ាងត្រឹមត្រូវ និងមានប្រសិទ្ធភាពនូវតួនាទី ភារកិច្ចរបស់ខ្លួន ក្នុងការរក្សាស្ថិរភាពសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន ហើយធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម ដែលធ្វើឱ្យបរិយាកាសនយោបាយទូទៅសំរាប់ការបោះឆ្នោតមានភាពប្រសើរ ។ ទាំងអស់នេះ គឺជាមោទនភាពដ៏ថ្លៃថ្លាណាស់សំរាប់ជាតិយើង ។

គណបក្សប្រជាជនកម្ពុជា សូមគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះបណ្តាប្រទេសជាមិត្ត សហគមន៍អ្នកផ្តល់ជំនួយ ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិនានាដែលបានគាំទ្រ និងជួយឧបត្ថម្ភយ៉ាងស្មោះដល់ដំណើរការបោះឆ្នោត ទាំងខាងសំភារៈ ស្មារតី និងបច្ចេកទេស ។ សូមថ្លែងអំណរគុណចំពោះក្រុមអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិទាំងអស់ ដែលបានអញ្ជើញទៅគ្រប់ច្រកល្ហកនៃទឹកដីកម្ពុជា ដើម្បីតាមដានពិនិត្យមើលយ៉ាងយកចិត្តទុកដាក់តាំងពីក្នុងដំណាក់កាលនៃយុទ្ធនាការឃោសនារហូតដល់ដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ហើយបានធ្វើការវាយតំលៃចំពោះដំណើរការបោះឆ្នោតនៅកម្ពុជានៅពេលនេះប្រកបដោយភាពយុត្តិធម៌ ។

ជនរួមជាតិជាទីគោរពស្នេហា ! ឆ្លងតាមលទ្ធផលនៃការបោះឆ្នោតលើកនេះ កាន់តែបង្ហាញយ៉ាងច្បាស់ថា ប្រជាជនកម្ពុជាមានគតិបណ្ឌិតគ្រប់គ្រាន់ក្នុងការធ្វើការសំរេចចិត្តខាងនយោបាយ ។ ប្រជាជនយើងមានបំណងប្រាថ្នា

និងក្តីសង្ឃឹមយ៉ាងខ្លាំងក្លាក្នុងការកសាងមាតុភូមិឲ្យចំរើនរុងរឿង រួចចាកផុតពីភាពក្រីក្រ មានជីវភាពរស់នៅ
បានសមរម្យ ប្រកបដោយកិត្តិយស និង សេចក្តីថ្លៃថ្នូរ ក្នុងសង្គមមួយ ដែលមានអរិយធម៌ ដ៏រុងរឿង ។

គណបក្សប្រជាជនកម្ពុជាសូមអះអាងជូនជនរួមជាតិថា គណបក្សនឹងបន្តប្រឹងប្រែងពេញទំហឹង ដើម្បីអនុវត្តកម្មវិធីនយោបាយដែលបានប្រកាសជូនជនរួមជាតិរួចហើយឱ្យបានសំរេច ស្របតាមការជឿទុកចិត្តរបស់ប្រជាជនចំពោះគណបក្ស ។ ក្នុងទិសដៅនេះ គណបក្សប្រជាជនកម្ពុជានឹងរៀបចំរាជរដ្ឋាភិបាលចំរុះមួយ សំរាប់អាណត្តិទី៣ ដែលមានសម្តេច **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ដើម្បីដឹកនាំប្រទេសជាបន្តទៀត ។ ការរិះគន់ ឬការប៉ុនប៉ងណាមួយ ដែលនាំកម្ពុជាចេញពីរង្វង់នៃរដ្ឋធម្មនុញ្ញបច្ចុប្បន្ន គឺជាការដើរថយពីចរន្តនៃលទ្ធិប្រជាធិបតេយ្យ និងជាសកម្មភាពផ្ទុយពីឆន្ទៈប្រជាជនតាមរយៈការបោះឆ្នោតកន្លងមក ដែលគណបក្សប្រជាជនកម្ពុជា មិនអាចទទួល យកបានឡើយ ។

សូមអំពាវនាវដល់ប្រជាជនកម្ពុជាគ្រប់រូប ទោះបានគាំទ្រគណបក្សណាក្តី សូមរក្សាភាពស្ងប់ស្ងៀម និងប្រកបការងារជាធម្មតា ដោយមិនជឿតាមពាក្យញុះញង់របស់អ្នកនយោបាយណា ដែលមានបំណងបង្កអស្ថិរភាពក្រោយការបោះឆ្នោត ។ យើងជាប្រជាជាតិខ្មែរតែមួយ យើងត្រូវរួមគ្នាជាកម្លាំងសាមគ្គីដ៏រឹងមាំ នៅក្រោមដំបូលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីកសាង និងការពារមាតុភូមិយើង ។ ភាពចំរុះខាងនយោបាយ គឺជាបញ្ហាដែលតែងកើតមានជាធម្មតាក្នុងរបបប្រជាធិបតេយ្យសេរីពហុបក្ស ប៉ុន្តែវាមិនមែនជាចំណុចនៃការបែកបាក់ជាតិឡើយ ព្រោះយើងមានគោលដៅរួមគ្នា គឺធ្វើឱ្យមាតុភូមិយើង ស្ថិតស្ថេរគង់វង្ស និងចំរើនរុងរឿង ។

គណបក្សប្រជាជនកម្ពុជាមានជំនឿថា គ្រប់ស្ថាប័នរបស់រាជរដ្ឋាភិបាល កម្លាំងប្រដាប់អាវុធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងបណ្តាមន្ត្រីរាជការទាំងអស់នឹងបន្តបំពេញភារកិច្ចការងារ រក្សាបានស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម ក្រោយពេលបោះឆ្នោត រហូតដល់រដ្ឋសភាថ្មី និងរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង ។

សូមគ្រប់គណបក្សនយោបាយ ទាំងគណបក្សដែលទទួលបានអាសនៈក្នុងរដ្ឋសភាថ្មី ក៏ដូចជាគណបក្សដែលពុំបានអាសនៈក្នុងរដ្ឋសភា សូមគិតដល់ផលប្រយោជន៍ជាតិជាធំ ហើយគោរពចំពោះការសំរេចចិត្តរបស់ប្រជាជន ដោយរួបរួមគ្នាទទួលយកលទ្ធផលនៃការបោះឆ្នោតនេះ ដើម្បីធានាឱ្យរដ្ឋសភានីតិកាលទី ៣ បានចាប់ផ្តើមការងាររបស់ខ្លួនយ៉ាងរលូន និងស្របតាមការកំណត់នៃរដ្ឋធម្មនុញ្ញ ។ នេះគឺជាការទទួលខុសត្រូវនៃគ្រប់គណបក្សនយោបាយ ចំពោះវាសនាប្រទេសជាតិ ដែលពង្រឹងបាននូវជំនឿរបស់ប្រជាជន ចំពោះមាគ៌ាប្រជាធិបតេយ្យ និងនីតិរដ្ឋ ។

ជាទីបញ្ចប់ ក្នុងនាមគណបក្សប្រជាជនកម្ពុជា ខ្ញុំសូមប្រកាសជាឧឡារិកថា ជោគជ័យនៃការបោះឆ្នោតជ្រើសតាំងរដ្ឋសភា នីតិកាលទី ៣ នេះ មិនមែនជាជោគជ័យសំរាប់តែគណបក្សនយោបាយណាមួយឡើយ ប៉ុន្តែជាជោគជ័យរបស់ប្រជាជនកម្ពុជាទាំងមូល ដែលស្រឡាញ់សន្តិភាព ស្ថិរភាព ប្រជាធិបតេយ្យ យុត្តិធម៌ និងអភិវឌ្ឍន៍ ។

សូមប្រគេនពរសម្តេចព្រះសង្ឃរាជ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមប្រសិទ្ធពរជូនជនរួមជាតិទាំងអស់ សូមបានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០៣

**ប្រធានគណបក្សប្រជាជនកម្ពុជា**